**វគ្គទី៣**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# គោរពផ្ញើជូនកម្មវិធីកូនខ្មែរពិត

អ្វីដែលខ្ញុំបានសន្យាចំពោះមិត្តអ្នកស្តាប់នោះគឺខ្ញុំពុងតែធ្វើហើយដរាបណាអ្នកទាំង អស់គ្នានៅតែចង់ដឹងថាតើ **ខ្ញុំជាអ្នកណា?**

នេះជាលើកទី៣ហើយដែលខ្ញុំមានវាសនា បានចូលរួមក្នុងកម្មវិធីរបស់អ្នក ។លិខិតលើកទី១និងលើកទី២របស់ខ្ញុំដែលបានផ្ញើរជូនកម្មវិធីនេះ ។វាគឺជាឱកាសដែលខ្ញុំបានបញ្ចេញនូវរឿងពិតទាក់ទងនិងជីវិតឯកជនរបស់ខ្ញុំ ។ ហើយខ្ញុំនិងបង្ហើរនូវបទពិសោធន៏ដ៏តិចតួចស្តួចស្តើងទាំងនេះសំរាប់ប្អូន១ជំនាន់ក្រោយអោយអ្នកបានយល់ពីអ្វីទៅជាការ តស៊ូ អំណត់ អត់ធន់ ទ្រាំទ្រការលំបាក ក្នុងបច្ចុប្បន្នកាលដើម្បីអោយអ្នកបានក្លាយជាមនុស្សដែលទទួលបានជោគជ័យនាពេលអនាគត ។ពេលដែលខ្ញុំបានផ្ញើរអត្ថបទជូនកម្មវិធីនេះ ច្បាស់ជាមានលោកអ្នកមួយចំនួនបានគិត ថានេះ ជាប្រលោមលោកដែលខ្ញុំនិពន្ធ ឡើងដើម្បី គ្រាន់តែកំសាន្តអារម្មណ៏ ឬ ជាអំនួតអោយអ្នកដ៏ទៃគិតថាខ្ញុំជាមនុស្ស អស្ចារ្យ ។ តែខ្ញុំចង់ជំរាបថា: ខ្ញុំគ្រាន់តែជាមនុស្សសាមញ្ញម្នាក់ប៉ុណ្ណោះ ខ្ញុំមិនបានខ្វល់ខ្វាយអ្វីទាំងអស់ចំពោះអ្នកដែលមានឧត្តមគតិបែបនេះព្រោះវាជារឿង ធម្មតាសំរាប់សង្គមមនុស្សហើយជាគំនិតនិងមតិរបស់គេផ្ទាល់ ។ សំខាន់បំផុតគឺខ្ញុំមាន ឱកាសបានបកស្រាយនូវជីវិតផ្ទាល់ខ្លួនរបស់ខ្ញុំសំរាប់មិត្តអ្នកដែលចង់ដឹងនិងចង់យល់តែប៉ុណ្ណោះ ។ខ្ញុំគ្មានបំណងណាមួយដើម្បីលើកិត្តិយសខ្ញុំអោយល្បីសុះសាយនោះទេ ។ ប៉ុណ្ណោះអ្នកនិងយល់ហើយបន្ទាប់ពីយល់ខ្ញុំនិងបង្ហើរនូវសាច់រឿងនៃវគ្គទីបីបន្តទៀត ។

អ្នកទាំងអស់គ្នានៅចាំបានទេថាវគ្គទី២ខ្ញុំស្លេះនូវកន្លែងណា? មិនចាំទេមែនទេ? អីចឹងខ្ញុំនឹងប្រាប់គឺខ្ញុំបានធ្វើដំណើរតាមផ្លូវលំនៃក្លោងទ្វារវត្តមួយសំដៅទៅភូមិដែលក្រុមគ្រួសារខ្ញុំរស់នៅ ។ ដើរបានមួយសន្ទុះយើងបានបត់ចូលខាងឆ្វេងដៃប្រមាណ៥០ម៉ែត្រ ហើយនៅខាងស្តាំដៃយើងបានចូលទៅដល់ផ្ទះមួយប្រក់ស្លឹកមានទំហំប្រហាក់ប្រហែល៤គុណ និង ៦ម៉ែត្រ ។លោកតាបានស្រែកហៅឈ្មោះ

អ្នកដែលនៅខាងក្នុងផ្ទះ ។អ្នកផ្ទះបានអុចជង្កៀងបំភ្លឺមើលស្រាប់តែសំឡេងស្រែកដ៏សែនរន្ធត់របស់លោកតាលោកយាយ និង ពូ មីង ស្រែកយំទ្រហឹងអ៊ឹងកងធ្វើអោយផ្អើលអស់អ្នកភូមិផងរបងជាមួយ ។ ពួកគាត់បានស្រវាអោបគ្នាយំសស្រាក់ហើយក៏ចាប់ផ្តើមរៀបរាប់ប្រាប់គ្នាទៅវិញទៅមកមិនអស់មិនហើយ ។ចំណែកខ្ញុំបានត្រឹមសំលឹងពួកគាត់ដោយ មិនបានដឹងអ្វីទាំងអស់ ។

សឹងតែពាក់កណ្តាលអាធ្រាត្រទៅហើយផ្ទះមួយនេះមិនទាន់បាត់លឺសំលេងជជែក យំយែករៀបរាប់នៅឡើយទេ ។ ប្រហែលជាលោកយាយគាត់សប្បាយចិត្តពេកក៏ភ្លេចខ្ញុំទុកចោល ស្រាប់តែគាត់នឹកឃើញក៏ស្រែកហៅខ្ញុំថាហ៎ ចៅមកនេះយាយភ្លេចប្រាប់ចៅ នេះហើយជាពូ មីង និង បងប្អូនជីដូនមួយរបស់ចៅ ជំរាបសួរពួកគាត់ទៅណា ខ្ញុំប្រៀបបាននិងមនុស្សខ្វាក់ ភ្នែក ទើបនិងព្យាបាលជា ។ ពុទ្ធោអើយខ្ញុំមាន ពូ មីង មាន បងប្អូន ហេតុអ្វី បានជាព្រហ្មលិខិតលេងសើច និង មនុស្សលោកយ៉ាងនេះ ។

មីងនិងពូបានសួរយាយថាគេជាកូនរបស់អ្នកណាម៉ែ? យាយឆ្លើយថា អើគឺវាជាកូនរបស់បងស្រីឯង ។ មីងបន្តទៀតថាខ្ញុំពិតជាដូចឪពុកខ្ញុំណាស់ តែខ្ញុំវិញមិនបានដឹងឡើយថា លោកពុកមានមុខមាត់យ៉ាងម៉េចទេ ។ ក្រោយពីរស់នៅទីនោះបានប្រហែលដប់ថ្ងៃខ្ញុំបានស្គាល់ បងប្អូន កាន់តែច្រើន ហើយរស់នៅជាមួយក្រុមគ្រួសារយ៉ាងកក់ក្តៅទោះបីជាពួកគាត់មិនមែនជា ឪពុក ម្តាយរបស់ខ្ញុំក៏ដោយ ។

លោកពូរបស់ខ្ញុំគាត់ជាគ្រូបង្រៀនម្នាក់ គាត់មានកូននៅក្នុងបន្ទុក៣នាក់ ចំណែកឯក្មួយ៧ដែលកំព្រាដូចខ្ញុំចំនួន៤នាក់បូករួមទាំងខ្ញុំទាំងយាយតាសរុប ចំនួន១២នាក់ ។

ហ៊ី! អ្នកសាកល្បងគិតមើលថាមុខរបរជាគ្រូបង្រៀនចិញ្ចឹម មនុស្សក្នុងបន្ទុកដល់ទៅ១២នាក់តើវាលំបាកប៉ុណ្ណា? គឺពិតជាលំបាកខ្លាំងណាស់ ណាមួយពួកកូន និង ក្មួយត្រូវស្ថិតក្នុងវ័យសិក្សា ។ លោកតាលោកយាយគាត់ពិបាកចិត្តណាស់ហើយគាត់បានគិតសារជាថ្មីថា ត្រូវមានគំរោងការយ៉ាងណាទៅមុខទៀត ។ទោះបីជាគាត់ខំគិតបែបណាក៏ គិតមិនចេញដែល ។ គិតទៅពេលវេលានៃការសប្បាយមិនបានយូឡើយសំរាប់គ្រួសារខ្ញុំ ។ ខ្ញុំមិនបាច់និយាយក៏អ្នករាល់គ្នាដឹងដែលថាការរស់នៅជាមួយនិងអ្នកដែលមិនមែនជាឪពុកម្តាយវាមិនមែនជាការងាយស្រួលឡើយ ទោះជាគេមិនស្តីថា តែយើងក៏មិនអាចដេកចាំតែទទួលទានបាននោះទេ ។តែពួកយើងទាំងអស់គ្នារកដំណោះស្រាយមិនឃើញដូច្នេះហើយ

ពួកយើង ត្រូវទ្រាំរស់នៅលំបាកលំបិនតទៅទៀត ។

បងប្អូនជីដូនមួយរបស់ខ្ញុំបានទៅសាលារៀនចំណែកខ្ញុំមិនទាន់បានចូលសាលាបន្តទៀតទេដោយមូលហេតុខ្ញុំទើបនិងផ្លាស់មកដល់ ។ស្ទើរតែរាល់ថ្ងៃពួកយើងបានដើរជញ្ជាត់ត្រី អូសឈ្នាង រាវខ្យង បេះត្រកួនព្រលឹត ដើម្បីសំរាប់ធ្វើជាអាហារបរិភោគ ។ហើយខ្ញុំគិតថាលោកអ្នកស្តាប់ទាំងអស់គ្នាក៏ធ្លាប់ជួបរឿងរ៉ាវបែបនេះដែលតើមែនទេ? ខ្ញុំរស់នៅបានរយះពេលជិតមួយឆ្នាំលោកពូបានត្រូវផ្លាស់ប្តូតំណែងគឺគាត់បានប្តូមកទីរួមខេត្ត ។ គាត់ត្រូវបានរដ្ឋអំណាចផ្តល់អោយនូវដីមួយកន្លែងសំរាប់សាងសង់ទីលំនៅ ដែលជាប់និងរបងសាលារៀន ។ពួកគាត់បានគិតគូពិចារណាហើយក៏សំរេចចិត្តចាកចេញពីទីលំនៅចាស់ ហើយមកសង់ផ្ទះតូចមួយសំរាប់រស់នៅ ។ ចំណែកលោកតាលោកយាយបានសង់ខ្ទមតូចមួយ នៅក្បែរនោះដែរ ។ តែខ្ទមលើកនេះមិនដូចនៅគីឡូម៉ែត្រលេខ៧ទេគឺប្រសើជាងមុនបន្តិច ។ លោកតាមិនបានបំភ្លេចអាជីបរបស់គាត់ជាជាងប៉ះកង់នោះទេ គឺគាត់នៅតែ ប្រកបរបរនេះដដែរ ។

ខ្ញុំបានត្រូវពូជួយអោយបានចូលរៀនបន្តទៀត ។ហើយជារឿយៗខ្ញុំមិនមានពេលទំនេរសោះឡើយក្នុងការបានទៅលេងដូចក្មេងដទៃទៀត ខ្ញុំត្រូវងើបពីព្រលឹមស្រាងៗជួយរៀបចំរទេះអូសទំនិញ ទៅផ្សារដែលមានចំងាយពីផ្ទះជិត២គីឡូម៉ែត្រដើម្បីអោយមីងរបស់ខ្ញុំគាត់លក់ដូរ ។បន្ទាប់មកខ្ញុំត្រូវមកជួយប៉ះកង់លោកតាហើយបើមិនសូវមានភ្ញៀវ ខ្ញុំនិង បងប្អូនជីដូនមួយខ្ញុំត្រូវដើរបេះស្លឹកអំពិលលក់ ខ្ញុំគ្មានប្រាក់សំរាប់ចាយវាយផ្តេសផ្តាសទេ ។

ពួកយើងលំបាកកាយតែពួកយើងមានសេចក្តីសុខជាបណ្តើរៗធ្វើអោយយើងរីករាយនិងការងារ ។

ខ្ញុំបានប្រឹងប្រែងបន្តការសិក្សារហូតដល់ថ្នាក់ទី១០ ។

ថ្ងៃមួយក្នុងឆ្នាំ១៩៩១លោកពូរបស់ខ្ញុំគាត់បានជិះម៉ូតូមួយគ្រឿងតែខ្ញុំមិនបានចាំម៉ាកទេហើយគាត់បានធ្វើដំណើរទៅភ្នំពេញដើម្បីមករៀនវគ្គបំពាក់បំប៉នរបស់គាត់ ។ក្នុងថ្ងៃដដែលនោះដែលស្រាប់តែមានដំណឹងមួយបានមកប្រាប់ដល់ពួកយើង ។ដំណឹងនោះគឺពូរបស់ខ្ញុំបានជិះម៉ូតូបុកគោស្លាប់ហើយ ។ រឿងដ៏អកុសលនោះបានធ្វើអោយក្រុមគ្រួសារយើងទាំងមូលស្រឡាំងកាំង ប្រមាណ២ម៉ោងក្រោយរថយន្តបានដឹកសពពូមកដល់ផ្ទះ ។គ្រាន់តែឃើញភ្លាមអ្នកមីងបានសន្លប់បាត់ស្មារតី ឯលោកតាលោក

យាយនិង ក្មេងៗបានស្រែកយំកងរំពងផ្អើលអស់មនុស្សម្នាលមកចោមរោមមើល ។

ពេលដែលមីងបានដឹងខ្លួនគាត់បានរត់ទៅអោបអង្រួនសាកសពពូដោយក្ដីស្ដាយស្រណោះអាលោះអាល័យជាពន់ពេកមីងមិនព្រមលែងដៃពីសពប្ដីគាត់ឡើយគាត់បានយំរៀបរាប់ទួញសោកវិយោគដែលមើលទៅគួរអោយសង្វេគរកទីបំផុតគ្មាន ។ ខ្ញុំនៅចាំសំដីមីងដែលគាត់បាននិយាយជាមួយសពពូថា បើអត់ពីពូទៅតើអោយគាត់រំពឹងអ្នកណាទៀត កូនៗទាំងអស់ពិតជាវេទនានិងកំព្រាហើយ ។ ហើយមីងបានអង្វសពពូអោយងើបឡើង និយាយមកកាន់គាត់ដូចសពមួយដង តែគ្មានទេពូមិនអាចនិយាយជាមួយគាត់បានទៀតទេ ។មីងបានស្រែកខ្លាំងៗសូមអោយទេវតាផ្ដល់នូវជីវិតប្ដីជាទីស្រលាញ់របស់គាត់មកវិញ ហើយគាត់សុខចិត្តស្លាប់ជំនួស ទោះជាត្រូវស្លាប់មិនចាប់ជាតិរាប់រយដងក៏ដោយ តែគ្មានប្រយោជន៏ទេ ពីព្រោះទេវតាបានចារួចទៅហើយ ។ នេះហើយគឺជាទឹកចិត្តដ៏សែនល្អបរិសុទ្ធដែលភរិយាគ្រប់រូបបានផ្ដល់ទៅអោយស្វាមី ។

អ្នកដែលឈរមើលទាំងប៉ុន្មាននាំគ្នាអាណិតអាសូរស្រក់ទឹកភ្នែកតាមគាត់គ្រប់ៗគ្នា ។មិនមែនដោយសារពូស្លាប់ទើបមីងគាត់ពោលពាក្យបែបនេះនោះទេតែវាជាការពិតដែលភរិយាស្ទើរតែគ្រប់រូបបានផ្ដល់ជូននូវទឹកចិត្តបែបនេះដល់ស្វាមី ។ ខ្ញុំសូមបើករង្វង់ក្រចកបន្ថិចពាក់ពន្ធ័ និងបញ្ហនេះ ។

ខ្ញុំបានសង្កេតឃើញភរិយាមួយចំនួនដែលសព្វថ្ងៃនេះពួកគាត់កំពុងតែត្រូវរស់រងទុក្ខលំបាកវេទនាដែលជាទង្វើរបស់ស្វាមីគាត់ផ្ដល់អោយ ។ តែក៏មានស្រ្ដីមួយចំនួនធំពួកគាត់បានជួបនូវស្វាមីដែលមានចិត្តបុណ្យចេះយល់អធ្យាស្រ័យនិងអោយតំលៃចំពោះភរិយា ។ ឱអ្នកដែលជាបុរសទាំងឡាយអើយ អ្នកមិនគួណាក្លាយខ្លួនជា មនុស្ស មិនស្គាល់តំលៃមនុស្សនោះទេ អ្នកត្រូវគិតថា ភរិយា របស់អ្នកប្រៀបដូចជាជីវិតរបស់អ្នក កូនរបស់អ្នកប្រៀបស្មើរនិងកែវភ្នែករបស់អ្នក ។

បើដូច្នេះហេតុអ្វីទើបអ្នកដាច់ចិត្តធ្វើអោយជីវិតពួកគេត្រូវរស់រងកម្មចាំតែទទួលនូវរឿងរ៉ាវដែលអ្នកផ្ដល់អោយគេទាវិញ? អ្នកបានចំណាយពេលវេលានៅខាងក្រៅផ្ទះបានយ៉ាងសប្បាយរីករាយអ្នកមានសេចក្ដីសុខជាមួយមនុស្សដែលមិនមែនជាជីវិតរបស់អ្នក ហើយអ្នកបែរជាផ្ដល់នូវទុក្ខអំពល់ដល់ ភរិយា ដល់កូន ដែលពួកគេទាំងនោះ គឺជាមនុស្សដែលគោរពនិងស្រលាញ់រូបអ្នកបំផុត ។

ខ្ញុំជឿជាក់ថានៅលើលោកនេះមានតែភរិយាអ្នកទេដែលហ៊ានស្លាប់ជំនួសអ្នកនិងធ្វើគ្រប់យ៉ាងដើម្បីអ្នកហើយខ្ញុំគិតថាសំរាប់អ្នកដទៃទេគេមិនអាចធ្វើដូចច្នេះដើម្បីអ្នកបានទេ ៕ខ្ញុំតំណាងអោយស្ត្រីនិងកូនខ្មែរមួយចំនួនដែលពួកគេកំពុងជួបប្រទះនូវរឿងបែបនេះសូមលើកដៃប្រណមលោកអ្នកដែលជាឪពុកសូមលោកមេត្តាឈប់ធ្វើបាបភរិយានិងកូនទៅទោះជាតាមរយះផ្លូវកាយឬផ្លូវចិត្តក្តី ពីព្រោះពួកគេមានសាច់មានឈាមមានបេះដូងដូចជាលោកអ្នកដែល ហើយពួកគេត្រូវការណាស់នៅភាពកក់ក្តៅពីអ្នកហើយសូមអ្នកចាំថាមានតែអ្នកទេដែលជាអ្នកធ្វើអោយសង្គមគ្រួសារអ្នកលិចឬអណ្តែតបាន ៕អ្នកគួតែអាណិតនូវសម្រែកដ៏សែនឈឺចាប់ដែលពួកគេបានអង្វរអ្នក ។ ឬក៏អ្នកមិនបានលឺទេ? អ្នកពិតជាបានលឺដូច្នេះសូមអាសូដល់ពួកគេផងព្រោះគេជាឈាមជ័របស់អ្នក ៕ហើយខ្ញុំក៏សូមអង្វរដល់ចិត្តអ្នកដែលធ្វើអោយគ្រួសារគេបែកបាក់គ្នា សូមអ្នកបញ្ឈប់នូវសកម្មភាពនោះទៅពីព្រោះខ្ញុំ គិតថាទេវតាមិនបានផ្តល់សេចក្តីសុខអោយអ្នកទេ ហើយអ្វីដែលអ្នកទទួលបាននូវពេលនេះវានិងរលាយបាត់នៅថ្ងៃស្អែកហើយបាបកម្មនិង នៅតែជាស្រមោលតាមលងបន្លាចអ្នកជានិច្ច ។

យើងទាំងអស់គ្នាពិតជាមានសំណាងណាស់ដែលមានវាសនាបានកើតជាមនុស្សចុះហេតុអ្វីយើងមិនខំសាងនូវអំពើល្អអោយបានច្រើន? ជាពិសេសគឺអ្នកបានកើតជាស្ត្រីខ្មែរ ៕បើដូច្នេះសូមអ្នកគិតពីវប្បធម៏ពីប្រពៃណី ពីទំនៀបទំលាប់ របស់ខ្មែរអោយបានច្បាស់លាស់ ។ ហើយយើងទាំងអស់គ្នានិងអាចជួយចូលរួមអោយសង្គមជាតិជួបនូវភាពរុងរឿងនិងថ្លៃថ្នូរ ។ ខ្ញុំមិនបានមានបំណង រិះគន់ឬ អប់រំអ្នកណាម្នាក់ឡើយ តែនេះគ្រាន់តែជាអ្វីដែលខ្ញុំធ្លាប់បានដឹង និងបានលឺតែប៉ុណ្ណោះ ។ ហើយវាពិតជាមានពិតនៅក្នុងសង្គមរបស់យើង ។ សូមអ្នកមេត្តាកុំខឹងនិងខ្ញុំណា៎

ខ្ញុំសូមបិទវង្វង់ក្រចកហើយសូមសាសព្ទនូវសាច់រឿងរបស់ខ្ញុំបន្តទៀត ៕ពួកយើងទាំងអស់គ្នាបានដង្ហែសពពូទៅបញ្ចុះ ។ តាមផ្លូវយើងមិនបានឮសំលេងអ្វីក្រៅអំពីការទួញសោក សំលេងខ្លងខែក ដែលបានស្រែកហៅព្រលឹងពូ អោយទៅឆ្ងាយ គ្មានថ្ងៃត្រឡប់ ដែលធ្វើអោយរន្ធត់ចិត្តរកទីបំផុតគ្មាន ។ បានមួយរយះពេលវែងពួកយើងបានរំសាយនូវទុក្ខព្រួយខ្លះៗតែយើងបានបាត់បង់នៅបង្គោលគ្រួសារដ៏ធំមួយដែលធ្វើអោយពួកយើងរិតតែជួបនូវទុកលំបាកទ្វេឡើង ។

ស្ទើតែគ្រប់ពេលវេលាខ្ញុំតែងតែទទួលបាននូវការអប់រំពីសំណាក់លោកតា លោកយាយ អ្នកមីង លោកគ្រូអ្នកគ្រូហើយខ្ញុំព្យាយាមយកពាក្យទូន្មានទាំងនោះមកធ្វើការពិចារណាជានិច្ច ។

អ្នកដឹងទេតាំងពីផ្លាស់ប្តូមកផ្ទះថ្មីនេះ ខ្ញុំបានខំចិញ្ចឹមមាន់ ទា យកពងលក់ អូសត្រី បេះស្លឹកអំពិល ប៉ះកង់  ដើរធ្វើការអោយគេ និងមានច្រើនយ៉ាងទៀតដែលមិនបានរៀបរ៉ាប់អស់ ។តែទាំងអស់ នេះ វាគឺជាបទពិសោធន៏និងជាមេរៀនសំរាប់ជីវិតរបស់ខ្ញុំ ។ ហើយអ្វីដែលខ្ញុំសប្បាយចិត្តនោះ គឺខ្ញុំបានរៀន រហូតដល់ថ្នាក់ទី១២ ហើយបានប្រលងជាប់ដែលជីវិតជាកូនកំព្រាដូចជាខ្ញុំអាចមានវាសនាល្អបែបនេះ ខ្ញុំមានមោទនះភាពចំពោះខ្លួនឯង និងបានធ្វើអោយលោកយាយលោកតាអ្នកមីងគាត់បានសប្បាយចិត្ត ។ អ្នកទាំងអស់ប្រហែលជាគិតថានេះជារឿងតូចតាច តែសំរាប់អ្នកក្រដូចជាខ្ញុំវាពិតជាធំធេងខ្លាំងណាស់ ។ ប៉ុន្តែអ្នកត្រូវចងចាំថាក្តីសប្បាយរបស់មនុស្សវាមានព្រំដែនកំណត់ ។ យ៉ាងណាម៉េញ សព្វ រុក្ខជាតិ មនុស្ស សត្វ ទាំងឡាយ សុទ្ធតែមិនទៀងទាត់ តែមានម្យ៉ាងដែលទៀងទាត់បំផុតសំរាប់យើង ។ តើជាអ្វីអ្នកដឹងទេ? គឺសេចក្តីស្លាប់ ហើយមនុស្សយើងម្នាក់ៗត្រូវរស់ដើម្បីស្លាប់ រស់រង់ចាំពេលវេលា ជីវិតប្រៀបបាននិងល្ខោនដែលបាននិពន្ធឡើងដោយវាសនា និងចាបញ្ចប់ដោយព្រហ្មលិខិត ។ ពោលដូចជាក្រុមគ្រួសារខ្ញុំជាដើម ព្រហ្មលិខិត និងមច្ចុរាជ បានមកបន្លាច ព្រមានក្រុមគ្រួសារខ្ញុំសាជាថ្មី គឺលោកយាយរបស់ខ្ញុំត្រូវមានជំងឺ ។ ពួកយើងខំរិះមធ្យោបាយគ្រប់បែបយ៉ាងដើម្បីជួយជីវិតយាយ តែយើងនៅតែមិនអាចជំនះនៅកំលាំងដ៏ឃោឃៅរបស់មច្ចុរាជបាន ។សង្ខាររបស់លោកយាយត្រូវបាន រលត់ផុតពីភពផែនដីយើងនេះទៅហើយ ។ លោកយាយដែលធ្លាប់តែញញឹម ធ្លាប់តែ សន្តោសប្រណី ធ្លាប់តែលួងលោម ថ្នាក់ថ្នមបំពេរចៅបីត្រកងលោមជាកំលាំងចិត្តចៅពីតូចរហូតពេលនេះស្រាប់តែ យាយស្អប់ចៅយាយចាកចេញឆ្ងាយពីចៅ យាយមិនញញឹមដាក់ចៅទៀតទេ ។

ខ្ញុំអង្គុយលុតជង្គង់នៅចុងជើងសពយាយហើយបានយំរៀបរាប់ប្រាប់សពយាយថា:

យាយទោះបីជាតិនេះចៅគ្មាន ម៉ែ គ្មានពុក តែចៅមានយាយជាអ្នកថែទាំ ចុះពេលនេះយាយទៅណា ចោលចៅ?យាយឈប់ស្រលាញ់ចៅហើយមែនទេ? ខ្ញុំបានជំរាបសពយាយជាចុងក្រោយថា :

យាយចៅស្រលាញ់យាយណាស់ ចៅអាណិតយាយណាស់ យាយមិនដែលបានស្គាល់អ្វីទៅដែលហៅ

ថាសេចក្តីស្រណុកនោះទេ យាយលំបាកណាស់រហូតដល់ពេលស្លាប់ ។អោយចៅសូមទោសផងណាយាយ ដែលចៅមិនបានតបស្នងសងគុណអ្នកសូម្បីតែបន្តិចណាឡើយយាយអត់ទោសអោយចៅផង ចៅសន្យាចំពោះយាយថាចៅនិងធ្វើគ្រប់យ៉ាងតាមបណ្តាំដែលយាយផ្តែផ្តាំហើយនិងមិនធ្វើអោយយាយខកបំណងទេ ។ ហើយបើជាតិក្រោយប្រាកដជាមានមែនចៅសូមផ្សងអោយជួបអ្នកគ្រប់៧ជាតិសូមយាយទៅអោយបានសុខចុះ ។

យាយនៅតែញញឹមរហូតធ្វើអោយពួកយើងមិនចង់អោយគេយកសពរបស់យាយទៅណាទាំងអស់ ។ខ្ញុំស្រណោះរាល់អនុស្សាវរីយ៍ដែលយាយនិងខ្ញុំធ្លាប់មានតាំងពីខ្ញុំដឹងក្តីមក ។ ខ្ញុំគ្មានពុកខ្ញុំគ្មានម៉ែតែពេលនេះខ្ញុំត្រូវបាត់បង់យាយម្នាក់ទៀត ។ហើយអ្វីដែលធ្វើអោយខ្ញុំស្លុតរន្ធត់និងរំជួលចិត្តរកទីបំផុតនោះគឺលោកតាបានសំរក់ទឹកភ្នែករហូតហើយគាត់មិនបានដើរចេញឆ្ងាយពីសពភរិយាជាទីស្រលាញ់របស់គាត់ឡើយ ។ ប៉ុន្តែគាត់មិនអាចធ្វើអ្វីអោយបានលើសពីការសំរក់ទឹកភ្នែកនោះទេ ។ខ្ញុំយល់យ៉ាងច្បាស់នូវទំហំទុក្ខរបស់គាត់ ហើយអ្វីដែលធ្វើអោយខ្ញុំចងចាំមិនភ្លេចនោះ គឺ ទោះជាគ្រួសារយើងក្រីក្រតែលោកតាលោកយាយមិនដែលមានជំលោះឈ្លោះទាស់ទែងគ្នាឡើយពួកគាត់ស្រលាញ់គ្នាណាស់ ហើយគាត់មិនដែលរស់នៅឃ្លាតឆ្ងាយពីគ្នាទេ ។តែពេលនេះលោកតាជាទីស្រលាញ់របស់ខ្ញុំត្រូវរស់នៅក្នុងខ្ទមដ៏កំសត់តែម្នាក់ឯងដោយមិនមានវត្តមានយាយនៅជាមួយគាត់ដូចពេលមុនទៀតឡើយ ។ខ្ញុំតែងសង្កេតឃើញលោកតាអង្គុយសំកុកហើយមានពេលខ្លះគាត់មិនបាននិយាយជាមួយអ្នកណា គាត់មិនពិសារបាយ គាត់មិនសំរាន្តយើងទាំងអស់គ្នាពិបាកចិត្តនិងគិតពីគាត់ ។ ខ្ញុំតែងតែជួយលួងលោមតារហូត តែស្ទើរតែគ្រប់ពេលគាត់បែរជាញញឹមឆ្លើយតបមកវិញថា:តាមិនអីទេចៅ កុំបារម្ភ៏ តែគ្រប់សំដីរបស់តាគឺបង្កប់ទៅដោយទុក្ខកង្វល់ និង ភាពឈឺចាប់ស្តាយស្រណោះ ។

បានប្រមាណ៧ខែក្រោយលោកយាយស្លាប់លោកតាបានធ្លាក់ខ្លួនឈឺម្នាក់ទៀត ។ លើកនេះធ្វើអោយយើងទាំងអស់គ្នាត្រូវភិតភ័យតក់ស្លុតបារម្ភ៏ចំពោះរូបគាត់ជាខ្លាំង ។ តែការពិតនៅតែការពិតយើងជាមនុស្សមិនអាចជំនះនៅកំលាំងដ៏មហិមារបស់មច្ចុរាជបានឡើយ ។ លោកតាត្រូវបានព្រហ្មលិខិតបញ្ចប់នៅវាសនារបស់គាត់តែត្រឹមនេះដោយជៀសមិនរួច ។ ក្រុមគ្រួសាររបស់ខ្ញុំប្រញ្រៀបបាននិងត្រូវបណ្តាសា

របស់អទិទេពពួកយើងត្រូវបាត់បង់មនុស្សជាទីស្រលាញ់ដល់ទៅ៣នាក់ក្នុងរយះពេល២ឆ្នាំ ។ ម្តាយមីងរបស់ខ្ញុំស្ទើរក្លាយជាមនុស្សឆ្កួត ចំណែកខ្ញុំមិនខុសពីលើកមុនៗទេគឺបានត្រឹមតែសម្រក់ទឹកភ្នែក ។មនុស្សយើងម្នាក់ៗពិតជាគ្មានអ្វីត្រូវស្តាយជាងត្រូវមនុស្សជាទីស្រលាញ់ចាកចេញពីយើងដោយគ្មានថ្ងៃត្រឡប់នោះទេ ។ហើយអ្វីដែលធ្វើអោយខ្ញុំស្តាយបំផុតនោះ គឺរូបខ្ញុំនេះមិនទាន់បានសងគុណលោកទាំងអស់ឡើយ ។ឆាកជីវិតលោកតាលោកយាយ ជួបតែទុក្ខវេទនារហូតដល់ពេលដែលលោកត្រឡប់ទៅវិញ ។ ប្រហែលជាជាតិមុនខ្ញុំបានសាងបាបកម្ម និងអំពើអាក្រក់ច្រើនពេកទើបជាតិនេះខ្ញុំមានកម្មធ្ងន់ធ្ងរយ៉ាងនេះ ។ ហឺ! តាំងពីអត់ពីលោកតាលោកយាយទៅខ្ញុំក្លាយជាមនុស្សឯការ តែគោលគ្មានគោដៅណាមួយអោយប្រាកដនោះឡើយ ។ ខ្ញុំក៏បានសំរេចចិត្តលាមីង លាបង លាប្អូនទាំងអស់ធ្វើដំណើរផ្សងព្រេងតែម្នាក់ឯងដើម្បីមករកការងារធ្វើនិងដើម្បីបានរៀនសូត្របន្តទៀតនៅឯទីក្រុងភ្នំពេញ ។

ខ្ញុំសូមផ្អាកការបរិយាយសាច់រឿងត្រឹមប៉ុណ្ណេះសិនចុះហើយសន្យាថាខ្ញុំនិងសរសេរនូវរឿងរ៉ាវនៃជីវិតពិតរបស់ខ្ញុំបន្តទៅទៀតនៅវគ្គក្រោយ ។មិនដឹងថាថ្ងៃស្អែកឬពេលណាទេខ្ញុំនិងផ្ញើទៅអ្នកទៀត ។ ខ្ញុំសូមអគុណចំពោះអ្នកទាំងអស់គ្នាហើយគិតថាសំបុត្រនេះនិងបានលឺជាលើកទីបីនិងរៀងរហូត ។ វគ្គទី៣នៃសំណេ **ខ្ញុំជាអ្នកណា?**

ភ្នំពេញថ្ងៃទី១៩ខែឧសភា ឆ្នាំ២០០៨

ពីខ្ញុំជាអ្នកណា